# វប្បធម៌នៃតំបន់ ទីប៉ាសា

ទីប៉ាសា (Tipasa) គឺជាតំបន់ជួញដូរពាណិជ្ជកម្ម និងជាតំបន់វប្បធម៌ដ៏សំខាន់មួយនៅសម័យកាល Punic បុរាណ (ស.វ.ទី ៦មុនគ.ស. រហូតដល់ស.វ.ទី៦នៃគ.ស.) ដែលស្ថិតនៅក្នុងតំបន់មហាសមុទ្រមីឌីទែរ៉ាណេ បច្ចុប្បន្នស្ថិតនៅក្នុងប្រទេសអាល់ហ្សេរី (Algeria)។ តំបន់នេះមានចម្ងាយ៧០គីឡូ ខាងលិចពីទីក្រុងAlgiers នៃប្រទេសអាល់ហ្សេរី[១] (រូបលេខ១-២)។

ទីប៉ាសា គឺជាតំបន់ស្ថានីយបុរាណវិទ្យាដ៏សំខាន់នៅក្នុងតំបន់ Maghreb ដែលស្គាល់ថាផ្នែកមួយនៃអាហ្វ្រិកខាងលិច បច្ចុប្បន្នរួមមានប្រទេស អាល់ហ្សេរី លីប៊ី ម៉ូរ៉ូកូ និងទុយនេស៊ីជាដើម។ នៅតំបន់ទីប៉ាសានេះ មានទីតាំងស្ថានីយសំខាន់ចំនួន៣ គឺពីរជាសំណង់ទីក្រុងនិងសំណង់ស្ថាបត្យកម្មសំខាន់ៗ និងមួយទៀតជាតំបន់នៃផ្នូរស្តេច ដែលហៅថា Royal Mauritanian Mausoleum[២] ( រូបលេខ៣-៤)។ តំបន់នេះគឺជាផ្នែកដ៏សំខាន់នៃការទំនាក់ទំនងរវាងអរិយធម៌ផ្សេងៗរួមមាន ផូនិច (Punic) រ៉ូមាំង (Roman) និងកាតាស (Carthage)ជាដើម។ នៅក្នុងអំឡុងសម័យកាលនោះ ទីប៉ាសា បានដើរតួយ៉ាងសំខាន់ដែលជាកំពង់ផែពាណិជ្ជកម្មផ្លាស់ប្តូរទំនិញជាមួយនឹងតំបន់ផ្សេងៗទៀតផង និងជាមជ្ឈមណ្ឌលសាសនាផងដែរ។[៣] យោងតាមសិលាចារឹកដំបូងបង្អស់នៅក្នុងទីប៉ាសាមានកាលបរិច្ឆេទឆ្នាំ២៣៨នៃគ.ស. ហើយដែលបានបង្ហាញអំពីការសាងសង់សំណង់អាគារសាសនាមួយចំនួនធំដែលចាប់ពីសតវត្សទី៣ និងទី៤នៃគ.ស. ដោយស្ថិតនៅក្នុងសម័យកាលរ៉ូមាំង។ សំណង់ស្ថាបត្យកម្មជាច្រើនត្រូវបានសាងសង់ឡើងនៅក្នុងតំបន់ទីប៉ាសា រួមមានសំណង់ផ្នូរ Royal Mauritanian Mausoleum កសាងនៅស.វ.ទី៣ មុនគ.ស. អំឡុងពេលស្ថិតនៅក្នុងរជ្ជកាលស្តេច Juba II និងសំណង់សំខាន់ជាច្រើនទៀត។[៤] សំណង់ស្ថាបត្យកម្មទាំងនោះ

[១] https://whc.unesco.org/en/news/178

[២] Tipasa - UNESCO World Heritage Centre

[៣] Ibid

[៤] https://www.worldhistory.org/image/9093/royal-mausoleum-of-mauretania/

អត្ថបទដោយ៖ អេង តុលា

មានភាគច្រើនកសាងអំពីថ្ម និងឥដ្ឋ ដែលមានការតុបតែងដោយ Mosaic ជាដើម។ ឧទាហរណ៍ សំណង់ផ្នូរ Royal Mauritanian Mausoleum គឺកសាងអំពីថ្ម ដាក់ពីលើគ្នា មានរាងមូលខ្ពស់ ដោយមានចម្លាក់ជាសិល្បៈសសររ៉ូមាំងជាច្រើននៅជុំវិញ។

នៅឆ្នាំ៤៣០នៃគ.ស. តំបន់នេះមានការឈ្លានពានពីសំណាក់ពួក វ៉ាន់ដាល់ ដែលបានវាយលុកក្នុងតំបន់ Maghreb និងបានគ្រប់គ្រងនៅតំបន់ទីប៉ាសា។ វ៉ាន់ដាល់ គឺជាក្រុមជនជាតិអាឡឺម៉ង់ដែលកកើតឡើងនៅស.វ.ទី១នៃគ.ស. និងបានបន្តរីកចម្រើនរហូតដល់ក្លាយជារដ្ឋមួយដែលអាចឈ្លានពានតំបន់ជាច្រើន ក្នុងនោះក៏មានតំបន់ទីប៉ាសាពីសំណាក់អាណាចក្ររ៉ូមាំងដែរ។[៥] នៅឆ្នាំ៥៣១នៃគ.ស មានអាណាចក្រថ្មីមួយទៀតដែលមានឈ្មោះប៊ីហ្សង់ទិន ក៏បានវាយលុក និងគ្រប់គ្រងតំបន់ទីប៉ាសានេះបន្ត។[៦]

សរុបមកទីប៉ាសា គឺជាតំបន់មជ្ឈមណ្ឌលពាណិជ្ជកម្ម និងជាតំបន់វប្បធម៌ដ៏សំខាន់នៅក្នុងតំបន់អាហ្វ្រិកខាងលិច ដែលបានបង្ហាញតាមរយៈសំណង់ស្ថាបត្យកម្ម និងសិលាចារឹកនៅទីនោះ។ ប្រវត្តិសាស្ត្រនៅក្នុងតំបន់នេះ គឺបានបង្ហាញអំពីការគ្រប់គ្រងដោយអាណាចក្រជាច្រើនជាបន្តបន្ទាប់ដូចជា រ៉ូមាំង នៅស.វ.ទី៣ វ៉ាន់ដាល់ ស.វ.ទី៥ និងប៊ីហ្សង់ទិន នៅស.វ.ទី៦។ នៅឆ្នាំ១៨៥៧ តំបន់ទីប៉ាសា ត្រូវបានបង្កើតជាទីក្រុងថ្មីមួយ ដែលមានប្រជាជនរស់នៅច្រើន និងបន្តជាតំបន់ពាណិជ្ជកម្មរហូតមកដល់សព្វថ្ងៃនេះ។ ស្ថានីយបុរាណនេះ ក៏ត្រូវបានចូលបញ្ជីបេតិកភណ្ឌពិភពលោកក្នុងឆ្នាំ១៩៨២ ក្នុងទំហំប្រមាណជាង៥២ហិតា៕

[៥] https://www.worldhistory.org/Vandals/

[៦] https://whc.unesco.org/en/list/193/

អត្ថបទដោយ៖ អេង តុលា



រូបលេខ១-២៖ សំណង់ស្ថាបត្យកម្មនៅស្ថានីយបុរាណវិទ្យាទីប៉ាសា

ប្រភព៖ Unesco



អត្ថបទដោយ៖ អេង តុលា



រូបលេខ៣-៤៖ សំណង់ផ្នូរ Royal Mauritanian Mausoleum ដែលមានការរចនាជាចម្លាក់សសរនៅជុំវិញ

ប្រភព៖ Unesco







# ឯកសារយោង

https://whc.unesco.org/en/news/178

Tipasa - UNESCO World Heritage Centre

https://www.worldhistory.org/image/9093/royal-mausoleum-of-mauretania/

https://www.worldhistory.org/Vandals/

https://whc.unesco.org/en/list/193/

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ អេង តុលា